ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តត្បូងឃ្មុំ**
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៨
ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ ៤០៩
ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ១៩៦
ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១
**សាលក្រមព្រហ្មទណ្ឌ**
**លេខ ១១៥ "គ"**
**ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០២៣**

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តត្បូងឃ្មុំ

បានបើកសវនាការជាសាធារណៈនាថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២៣ នៅសាលាដំបូងខេត្តត្បូងឃ្មុំ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តត្បូងឃ្មុំ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តត្បូងឃ្មុំ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តត្បូងឃ្មុំ

## ដើម្បីជំនុំជម្រះលើៈ

១. ឈ្មោះ [redacted] ទ្រី ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ កម្រិតវប្បធម៌ថ្នាក់ទី១២ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិសំបូរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ[redacted]ស៊ីណាន មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ [redacted]យ៉ង "រស់" ម្តាយឈ្មោះ [redacted]រឿន "រស់" ជាជនជាប់ចោទ ប្រវត្តិផ្តន្ទាទោសពីមុនដោយតុលាការ គ្មាន ។ *(ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការលេខៈ ៥៤៤ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០)* ។

២. ឈ្មោះ [redacted] ស៊ីណាន ភេទស្រី អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើចំការ កម្រិតវប្បធម៌ថ្នាក់ទី៦ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិសំបូរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ស្ថានភាពគ្រួសារប្តីឈ្មោះ[redacted] ទ្រី មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ[redacted] ឃុន "ស្លាប់" ម្តាយឈ្មោះ [redacted]អូន "ស្លាប់" ជាជនជាប់ចោទ ប្រវត្តិផ្តន្ទាទោសពីមុនដោយតុលាការ គ្មាន ។ *(ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការលេខៈ ៥៤៦ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០)* ។



Scanned with CamScanner

ជាប់ពីបទ៖ **"រំលោភលើទំនុកចិត្ត"** ប្រព្រឹត្តនៅចំណុចភូមិសំបូរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៣. ឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ជ័រកៅស៊ូ កម្រិតវប្បធម៌ថ្នាក់ទី ១២ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិត្រមូង ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] សុភ័ស្ត មានកូនចំនួន ០១នាក់ ឪពុកឈ្មោះ [redacted] ទ្រី "រស់" ម្តាយឈ្មោះ [redacted] ស៊ីណាន "រស់" ជាជនជាប់ចោទ ប្រវត្តិផ្តន្ទាទោសពីមុនដោយតុលាការ គ្មាន ។

*(ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការលេខ: ៥៤៦ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០)* ។

ជាប់ពីបទ៖ **"ធ្វើឱ្យខូចខាតដោយចេតនា"** ប្រព្រឹត្តនៅចំណុចភូមិសំបូរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឈុនអេង** ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីចូលនិវត្តន៍ ទីកន្លែងកំណើតភូមិកំពង់សាឡាង ឃុំកំពង់ចាម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិខ្នងក្រពើកើត ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] អេងហួរ "ស្លាប់" ម្តាយឈ្មោះ [redacted] គីមឈន់ "រស់" ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] ដេត មានកូនចំនួន ០៥នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុនដោយតុលាការ គ្មាន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ដេត** ភេទស្រី អាយុ ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេផ្ទះ មានទីលំនៅបច្ចុប្បន្នរស់នៅភូមិខ្នងក្រពើកើត ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ស្ថានភាពគ្រួសារប្តីឈ្មោះ [redacted] ឈុនអេង មានកូនចំនួន ០៥ នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុនដោយតុលាការ គ្មាន ។

## អង្គហេតុនៃបទល្មើសដែលចោទប្រកាន់

កាលពីអំឡុងឆ្នាំ២០០៦ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈុនអេង និងប្រពន្ធឈ្មោះ [redacted] ដេត បានឱ្យជនជាប់ចោទឈ្មោះ [redacted] ទ្រី និងប្រពន្ធឈ្មោះ [redacted] ស៊ីណាន ព្រមទាំងកូនឈ្មោះ [redacted] វិចិត្រ មកចាំចម្ការថែទាំដំណាំ និងឱ្យរស់នៅផ្ទះរបស់ខ្លួនដែលបានសាងសង់លើដីចម្ការនោះដែលមានទីតាំងស្ថិតនៅភូមិសំបូរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។ ស្រាប់តែនៅឆ្នាំ២០១៤ ជនជាប់ចោទឈ្មោះ [redacted] ទ្រី និងប្រពន្ធឈ្មោះ [redacted] ស៊ីណាន បានទៅនិយាយភូតភរកុហកអាជ្ញាធរ ដើម្បីឱ្យអាជ្ញាធរចេញលិខិតបញ្ជាក់លើដី និងផ្ទះខាងលើថាជាដី និងផ្ទះរបស់ខ្លួន ។ ក្នុងគោលបំណងយកទៅដាក់ធនាគារ ដើម្បីខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត គីអិលស៊ី ជាបន្តបន្ទាប់ ក្រោយមកដើមបណ្តឹងបានដឹងពីបញ្ហានេះក៏មានការប្តឹងផ្តល់គ្នាហើយនៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បានធ្វើសកម្មភាពវាយបំផ្លាញរបងទ្វារធ្វើពីដែករបស់ដើមបណ្តឹងដែលបានសាងសង់នៅទីតាំងដីខាងលើបណ្តាលឱ្យខូចខាត

-**បានឃើញ** ពាក្យបណ្តឹងចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ របស់ដើមបណ្តឹងឈ្មោះ [redacted] ឈុនអេង និងប្រពន្ធឈ្មោះ [redacted] ដេត ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៩២ អ.យ.ង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១២២ អ.យ.ង ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៥១ ព្រ.១១ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តត្បូងឃ្មុំ ។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌចាត់របៀបលេខ ២០២ "គ" ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តត្បូងឃ្មុំ ។

-**បានឃើញ** សាលដីកាលេខ ៤៦ ព្រ.ទ ក្រ II (វ.ធ) ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ។

-**បានឃើញ** ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៣៥៦ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] ទ្រី បានឆ្លើយថា៖ ដីដែលខ្លួនកំពុងរស់នៅសព្វថ្ងៃនេះមានទំហំ ២ ហិចតា និង ៧ អាជាង ដោយមានការទិញលក់បន្ថែមជាបន្តបន្ទាប់ហើយក៏មានអាជ្ញាធរដឹងឮផងដែរ ។ ចំពោះដីនេះខ្លួនចូលមករស់តាំងពីឆ្នាំ២០០៦ មកម្លេះ ។ ក្រោយមកនៅឆ្នាំ២០១៣ ខ្លួនបានសាងសង់ផ្ទះនៅលើដីនេះ ដោយមានការខ្វះខាតខ្លួនក៏បានខ្ចីលុយពីធនាគារក្នុងឆ្នាំ២០១៤ ។ ចំពោះគេចោទប្រកាន់ថាខ្លួនត្រូវបានរស់នៅគេនោះវាមិនត្រឹមត្រូវទេ ។ ចំពោះដីដែលខ្លួនកំពុងរស់នៅនោះគឺមានស្រះ ការជីកស្រះនេះគឺខ្លួនបានជួលគ្រឿងចក្ររបស់ដើមបណ្តឹងហើយពេលទៅជួលជីកនោះគឺមានវត្តមានរបស់ម្ចាស់គ្រឿងចក្រដែរ តែមិនបាននិយាយពីអ្វីទេចំណែកតម្លៃជួលនោះខ្លួនភ្លេចបាត់ហើយ ដោយយកដីទាំងនោះទៅចាក់ពង្រីកលើដីធ្វើផ្ទះ ។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាន បានឆ្លើយថា៖ ខ្លួនបានរស់នៅលើសព្វថ្ងៃនេះតាំងពីឆ្នាំ២០០៦ មកម្លេះហើយនៅឆ្នាំ២០១៣ ខ្លួន និងប្តីបានធ្វើផ្ទះរស់នៅអស់ប្រហែល ២ ម៉ឺនដុល្លារអាមេរិក ។ ចំពោះការលើកឡើងរបស់ដើមបណ្តឹងថាខ្លួនមានការដោះដូរដីគ្នានោះវាមិនពិតនោះទេ ។ ចំពោះការទៅរស់នៅនោះដើមបណ្តឹងជាពូរបស់ខ្លួនគាត់ប្រាប់ថារស់នៅដីហ្នឹងទៅគ្មានអ្នកណារករឿងអីទេអ្នកណាក៏ទៅនៅដែរ ហើយនាងខ្ញុំក៏រស់នៅនិងធ្វើជាកម្មករកៅស៊ូនៅទីនោះរហូតដល់ឆ្នាំ២០១២ រោងចក្របានកាត់ដីឱ្យខ្លួន ទើបនាងខ្ញុំចាប់ផ្តើមសាងសង់នៅតែម្តង ដោយខ្លួននិងប្តីបានទិញពង្រីកបន្ថែមតែមិនមានប្លង់អីទេ ដោយសារតែដីតំបន់នោះជាដីរបស់រដ្ឋឱ្យនៅ

-ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បានឆ្លើយថា៖ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ត្រូវជាជីតារបស់ខ្លួន ហើយគាត់មិនដែលបានចិញ្ចឹមបីបាច់ខ្លួនអ្វីទេ ខ្លួនរស់នៅជាមួយឪពុកម្ដាយរហូតមកទល់ដឹងក្ដី ។ ចំពោះដើមបណ្ដឹងថាគាត់ជាអ្នកចំណាយលើរៀបការរបស់ខ្លួនគឺមិនពិតនោះទេ គាត់មិនបានរៀបចំការឲ្យខ្លួនទេ ខ្លួនគ្រាន់តែសុំផ្ទះរបស់គាត់ថតរូបតែប៉ុណ្ណោះព្រោះផ្ទះគាត់ធំហើយស្អាត ចំណែកការធ្វើឲ្យខូចខាតរបងអ្វីនោះខ្ញុំក៏មិនបានប្រព្រឹត្តដែរ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈុនអេង បានឆ្លើយថា៖ នៅក្នុងឆ្នាំ២០០៦ ខ្លួនបានទិញពីឈ្មោះ [redacted] វណ្ណា ចំនួន ០១ (មួយ) ហិចតា ក្នុងតម្លៃ ៤,០០០ (បួនពាន់ដុល្លារ) អាមេរិក ហើយដាំដើមទុរេនបានស្រាប់ហើយហើយមានស្រះស្រីស្រាប់ទៀតផង ចំពោះដីនោះខ្លួនរវល់ក៏បានឲ្យជនជាប់ចោទជាក្មួយមករស់នៅមើលថែព្រមទាំងមានក្មួយៗផ្សេងទៀត ។ ក្រោយមកឆ្នាំជិតការកូនវា (ចៅ) ទើបប្រពន្ធរបស់ខ្ញុំប្រាប់ឲ្យវាធ្វើផ្ទះឲ្យមានមុខមានមាត់ ចំពោះជាងកូនក្មួយជាអ្នករកខ្លួនឯង ចំពោះសម្ភារៈដូចជាស៊ីម៉ង់ ដែក ឥដ្ឋ ខ្ញុំជាអ្នកចេញលុយទាំងអស់ ចំពោះដីនោះខ្លួនមិនបានធ្វើប្លង់ទេ ដោយសារតែដីតំបន់នោះគ្មានក្រុមការងារវាស់វែងទៅដល់ចំណែករបងនោះខ្លួនបានសាងសង់មិនមែនជាដីក្រុមហ៊ុនទេ ចំពោះឈ្មោះ [redacted] វិចិត្រ ដែលបានទៅវាយនោះខ្លួនប្រាប់វាលែងឲ្យឈប់ចូលទទៀតហើយ ចំពោះដីទិញ ០១ (មួយ) ហិចតា ក្រោយមកខ្លួនបានយកគ្រឿងចក្រ ០៣ គ្រឿងទីជីកពង្រីកស្រះ ដីអ្នកភូមិចាក់បំពេញស្រែ ដីអ្វីដាំស្រូវ ។ ចំពោះឈ្មោះ [redacted] វិចិត្រ គឺនៅតាំងពីតូចមកម្ដងមានតាំងរូបថតទៀតផង ហើយពេលវាធំ ខ្ញុំ និងប្រពន្ធខ្លួនឲ្យវាទៅរៀនទៀតផងនៅភ្នំពេញ ។ កន្លងមកខ្លួនធ្វើជានគរបាលស្រុកតាំងពីឆ្នាំ ១៩៨៦-២០១២ ទើបចូលនិវត្តន៍ចំពោះម្ចាស់ដីចំការកៅស៊ូគឺជាពួកម៉ាកររបស់ខ្លួន ចំពោះដីដំបូងឡើយខ្លួនបានទិញពីឈ្មោះ [redacted] វណ្ណា ជាមេក្រុមបច្ចេកទេសហើយត្រូវបានម្ចាស់ក្រុមហ៊ុនឲ្យដីគាត់ ទើបនៅឆ្នាំ២០០៦ ឈ្មោះ [redacted] វណ្ណា បានលក់ដីឲ្យខ្ញុំឆ្នាំ២០០៦ ដដែល ក្រោយពេលទៅទិញរួចខ្លួនបានឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីណាន និងប្ដីរបស់វាមករស់នៅមើលថែព្រោះខ្លួនជាប់រវល់ តែខ្លួនមកមើលជារៀងរាល់ឆ្នាំ ទើបឆ្នាំ២០២០ ទេ ទើបលែងបានទៅ ។ យ៉ាងហោចណាស់ក្នុង ០១ (មួយ) ខែ ខ្លួនទៅ ៣ (ដង) ដែរ ហើយមានអ្នកដឹងឮតែខ្ញុំមិនបានហៅគេចូលរួមធ្វើជាសាក្សីទេ នៅក្នុងរឿងនេះដែលខ្លួនសុំទាមទារសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗជារួមគ្នាជាមួយប្រពន្ធជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដេត សរុបចំនួន ២០០ (ពីររយលាន) រៀល ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដេត បានឆ្លើយថា៖ កាលដើមឡើយខ្លួនទិញពីឈ្មោះ [redacted] វណ្ណា ព្រមទាំងមានចំនួន ០៤ ម្ចាស់ទៀត តែប្ដីរបស់ខ្លួនស្គាល់តែ ០២ ម្ចាស់ទេ ។ ចំពោះដីនោះមានទុរេន ម្រេច ចំប៉ាដក ជាដើម ដោយម្រេចដាំចំនួន ១,២០០ ជន្លង់ ហើយបច្ចុប្បន្ននេះក្មួយខ្ញុំវាសុះរើកម្ទេចអស់ហើយ ដោយដំណាំទាំងនោះក្មួយវាជាអ្នកមើលការខុសត្រូវ ហើយខ្លួនជាអ្នកចំណាយ ។ កូនក្មួយវារស់នៅជាមួយខ្ញុំតាំងពីតូចមកមែន ក្រោយមកនៅឆ្នាំ២០១៨ ខ្លួនចង់ធ្វើប្លង់ទៅរកទើបមិនមានឯកសារអ្វីទាំងអស់ ។ ដីដែលខ្លួនបានទិញនោះមិនមានប្លង់ទេតែមានបង្កាន់ដៃទុកក្នុងផ្ទះលើដីនោះធម្មតា ស្រាប់តែទៅរកឯកសារស្រាប់តែបាត់អស់ ។



Scanned with CamScanner

-សាក្សីឈ្មោះ[redacted]ទី (ជាមេភូមិ) បានឆ្លើយថា៖ ចំពោះដីទាំងនោះខ្លួនមិនបានដឹងថាមានប្លង់ ឬមិនមានប្លង់ទេខ្លួនមិនបានដឹងទេ គ្រាន់តែដឹងថាឈ្មោះ [redacted] ទ្រី និងប្រពន្ធវារស់នៅអចិន្ត្រៃយ៍រហូតមក និងមានគេដឹងឮជាច្រើន ដោយឡែកចំពោះឈ្មោះ[redacted] ឈុនអេង ខ្លួនមិនដែលស្គាល់ទេ ឮតែឈ្មោះ ។

-សាក្សីឈ្មោះ[redacted]ឡូ បានឆ្លើយថា៖ ខ្ញុំជាក្មួយរបស់ឈ្មោះ[redacted]ឈុនអេង ខ្លួនរស់នៅចំការចេក ចំពោះរឿងគាត់ឈ្លោះគ្នារឿងដីខ្លួនដឹងខ្លះៗដែរ ព្រោះដីនោះមានចម្ងាយពីផ្ទះរបស់គាត់មួយទៀតមានចម្ងាយប្រហែល ០១ គីឡូដី ខ្ញុំនៅផ្ទះគាត់បានប្រហែល ០៣ (បី) ខែ គាត់បានឲ្យខ្ញុំទៅឈាមនៅចំការចេកដីកន្លែងផ្សេងវិញ ចំពោះដីមានទំនាស់នោះឈ្មោះ [redacted] ទ្រី វាដំមានទុរេន មានខ្នុរផ្សេងៗទៀត ក្រោយមកទៀតខ្ញុំមិនដឹងទេ ។ ចំពោះដីនោះខ្ញុំច្បាស់ថាជាដីរបស់ឈ្មោះ[redacted] ឈុនអេង ព្រោះគាត់ទិញពីគេ ០៣ (បី) វគ្គ ។

-សាក្សីឈ្មោះ[redacted] ប៉ាំង (ជាមេឃុំ) បានឆ្លើយថា៖ ខ្លួនជាមេឃុំតាំងពីឆ្នាំ១៩៨៣ មកម្លេះ ចំពោះស្ថានភាពដីនោះមានដំណាំច្រើនប្រភេទ និងមានផ្ទះចំនួន ០៣ ខ្នង ។ ចំពោះផ្ទះរស់ដើមបណ្តឹងគឺមានចម្ងាយប្រហែល ១ (មួយ) គីឡូម៉ែត្រ ពីដីដែលមានទំនាស់ ។ ចំពោះដីតំបន់នោះជាដីរបស់រដ្ឋគ្រប់គ្រងដោយក្រុមហ៊ុនចំការកៅស៊ូ ក្រោយមកទើបនៅឆ្នាំ២០១២ មានក្រឹកលេខ ០០១/២០១២ របស់រាជរដ្ឋាភិបាលបានកាត់ដីជូនប្រជាពលរដ្ឋរស់នៅតំបន់នោះដែលមានទំហំប្រហែល ៥០០ ហិចតា ។ ក្នុងរឿងនេះដែលខ្លួនមិនបានដឹងថាដើមបណ្តឹងនៅលើដីទំនាស់ទេ ព្រោះខ្លួនឃើញតែឈ្មោះ [redacted] ទ្រី និងប្រពន្ធរបស់វារស់នៅ ។ ចំពោះរបងនោះដែលបាក់បែកអីនោះខ្លួនមិនបានដឹងទេ ចំពោះលិខិតបណ្តឹងជំទាស់នោះខ្លួនដំបូងឡើយធ្លាប់ចុះហត្ថលេខាឲ្យឈ្មោះ[redacted] ឈុនអេង តែមិនបានដឹងថាដីនោះមានទំនាស់ទេ តែខ្លួនសុំអះអាងថាខ្លួនមិនដែលចុះហត្ថលេខាលើដីរដ្ឋទេ ។

-សាក្សីឈ្មោះ[redacted] ញ៉ៅ បានឆ្លើយថា៖ កន្លងមកខ្លួនបានមករស់នៅជាមួយឈ្មោះ[redacted] ឈុនអេង តាំងពីឆ្នាំ១៩៩៥ មកម្លេះ កាលនោះម្តាយមីងគាត់មានកន្លែងអាឈើលក់ធ្វើអាជីវកម្ម ដោយគាត់តែងតែឲ្យលុយកាក់ចាយ រហូតមកដល់ឆ្នាំ១៩៩៨ ត្រូវបានបិទវិញ ។ ចំពោះឈ្មោះ [redacted]ឈុនអេង ជាប៉ូលីសណានោះខ្លួនមិនបានដឹងទេ ក្រោយមកនៅឆ្នាំ២០១២ ខ្លួនឈប់រស់នៅកន្លែងនោះហើយ តែខ្ញុំនៅតែចេញចូលយូរៗម្តងជាធម្មតាទេ ចំពោះការធ្វើផ្ទះនោះខ្លួនដឹងដែរថាគេធ្វើផ្ទះលើដីទំនាស់នោះក្នុងឆ្នាំ២០១៣ ។ ចំពោះដីទំនាស់នោះគឺពូ [redacted] ឈុនអេង គាត់ទិញពីមេជាងភ្លើងពីក្រុមហ៊ុនតែពេលនោះខ្ញុំចាកចេញលែងនៅកន្លែងគាត់ទៀតហើយ ខ្ញុំមិនដឹងថាគាត់ឲ្យអ្នកណាទៀតទេ ។

**-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី**

ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការរួចមក ដោយសារកន្លងមកខ្លួនបានដាក់ពាក្យបង្គង់នីតិវិធីរួចចូលមកម្តងរួចហើយ ដើម្បីរង់ចាំដាក់ភស្តុតាងបញ្ចូល ប៉ុន្តែរហូតមកដល់ពេលនេះក្នុងនាមជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីខ្លួនស្នើសុំតុលាការមេត្តាផ្តល់យុត្តិធម៌ដល់កូនក្តី និងធ្វើការផ្តន្ទាទោសតាមច្បាប់លើជនជាប់ចោទខាងលើ

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

យោងតាមសេចក្តីសន្និដ្ឋានការពារចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំង ០៣ (បី) នាក់ ខាងលើបានធ្វើសេចក្តីសន្និដ្ឋានការពារដូចខាងក្រោម៖

១. យោងតាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ឈុនអេង និងប្រពន្ធឈ្មោះ [redacted] ដេត ដែលបានឆ្លើយអះអាងនៅក្នុងសវនាការថាខ្លួនបានទិញដីទំនាស់ខាងលើក្នុងអំឡុងឆ្នាំ ២០០៤-២០០៦ ពេលនោះដីទំនាស់ខាងលើនៅជាកម្មសិទ្ធិរបស់រដ្ឋ ហើយត្រូវបានអាជ្ញាធរបដិសេធមិនទទួលស្គាល់ការទិញលក់នាពេលនោះឡើយ ហើយរដ្ឋទើបតែបានកាត់ឆ្វាលចែកឱ្យប្រជាពលរដ្ឋដែលបានចូលទៅកាន់កាប់ជាក់ស្តែង ក្លាយជាកម្មសិទ្ធិឯកជននៅក្នុងឆ្នាំ២០១២ តាមបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាលប៉ុណ្ណោះ ។

២. មួយវិញទៀត ដើមបណ្តឹងរដ្ឋប្បវេណីមិនដែលទៅស្នាក់នៅ និងបង្ហាញពីកិរិយានៃការកាន់កាប់លើដីទំនាស់ខាងលើឡើយ ហើយមកដល់ពេលនេះដើមបណ្តឹងមិនបានបង្ហាញភស្តុតាងបញ្ជាក់កម្មសិទ្ធិរបស់ខ្លួនលើដីនេះទេ ដូច្នេះបង្ហាញឱ្យឃើញថាដើមបណ្តឹងរដ្ឋប្បវេណីគ្មានសិទ្ធិលើកម្មសិទ្ធិដីទំនាស់ខាងលើឡើយ ។

៣. ផ្ទុយទៅវិញ កូនក្តីរបស់នាងខ្ញុំឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ស៊ីណាន បានចូលមករស់នៅកាន់កាប់ជាក់ស្តែងតាំងពីឆ្នាំ២០០៦ មកម្ល៉េះ ដោយបានសាង់សង់ផ្ទះ និងដាំដំណាំជាច្រើនមុខលើដីទំនាស់ខាងលើ ហើយក៏បង្ហាញពីកិរិយានៃការកាន់កាប់ស្របច្បាប់ ដោយពុំដែលមានការប្តឹងជំទាស់ពីបុគ្គលណាឡើយ ។

៤. មិនត្រឹមតែប៉ុណ្ណោះ ក៏មានសាក្សីជាច្រើននាក់ដែលជាប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ក្នុងភូមិសំបូរតាំងពីឆ្នាំ២០០៦ និងអាជ្ញាធរមូលដ្ឋានគឺលោកមេឃុំ និងមេភូមិ រួមគ្នាចូលមកឆ្លើយបំភ្លឺនៅដំណាក់កាលស៊ើបសួរ និងនាពេលសវនាការថាកូនក្តីរបស់នាងខ្ញុំពិតជាបានកាន់កាប់ ប្រើប្រាស់ អាស្រ័យផលលើដីទំនាស់ តាំងពីឆ្នាំ២០០៦ ដូចការឆ្លើយបញ្ជាក់របស់កូនក្តីនាងខ្ញុំមែន ។ ហើយកូនក្តីរបស់ខ្ញុំមានភស្តុតាងជាឯកសារត្រឹមត្រូវបញ្ជាក់ពីសិទ្ធិកាន់កាប់របស់ខ្លួន ហើយមានស្នាមម្រាមដៃរបស់ប្រជាពលរដ្ឋចំនួន ៨០នាក់ ដែលផ្តិតមេដៃទទួលស្គាល់ការកាន់កាប់របស់កូនក្តីនាងខ្ញុំផងដែរ។

៥. យោងតាមមាត្រា ៣០ នៃច្បាប់ភូមិបាលស្តីពីលទ្ធកម្មនៃកម្មសិទ្ធិបានកំណត់ថាចំពោះបុគ្គលដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំយ៉ាងតិច ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធស្ថាពរ ដូច្នេះសកម្មភាពដែលកូនក្តីរបស់នាងខ្ញុំបានដាក់ពាក្យស្នើសុំចុះបញ្ជី និងសុំឱ្យអាជ្ញាធរចេញលិខិតបញ្ជាក់ពីកម្មសិទ្ធិ គឺត្រឹមត្រូវតាមច្បាប់ពុំមែនជាអំពើរំលោភលើទំនុកចិត្តឡើយ។

៦. រីឯការចោទប្រកាន់លើកូនក្តីរបស់នាងខ្ញុំឈ្មោះ [redacted] វិចិត្រ ពីបទធ្វើឱ្យខូចខាតដោយចេតនាគឺពុំត្រឹមត្រូវឡើយ ដោយសារតែក្នុងថ្ងៃកើតហេតុ កូនក្តីរបស់យើងខ្ញុំពុំមានវត្តមាននៅទីកន្លែងកើតហេតុទេ ហើយក៏ពុំមានភស្តុតាង ឬសាក្សីណាម្នាក់អះអាងថាបានឃើញកូនក្តីរបស់នាងខ្ញុំបានប្រព្រឹត្តសកម្មភាព វាយបំផ្លាញរបងនោះដែរ សូម្បីតែដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ក៏មិនបានឃើញផ្ទាល់ភ្នែកដែរ ដោយគ្រាន់តែឮគេថាហើយធ្វើការ

ចោទប្រកាន់លើកូនក្តីរបស់នាងខ្ញុំ ដោយគ្មានមូលដ្ឋានច្បាស់លាស់ ដូច្នេះតាមរយៈអង្គហេតុខាងលើបង្ហាញថា គ្មានភស្តុតាងដាក់បន្ទុកលើកូនក្តីរបស់នាងខ្ញុំឈ្មោះ [redacted] វិចិត្រ ឡើយ ដែលជាគោលការណ៍វិមតិសង្ស័យត្រូវបាន ជាប្រយោជន៍ដល់ជនសង្ស័យ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមតុលាការមេត្តាសម្រេចឱ្យកូនក្តីរបស់ខ្លួនទាំងបីឈ្មោះ [redacted] ទ្រី ,ឈ្មោះ [redacted] ស៊ីណាន និងឈ្មោះ [redacted] វិចិត្រ បានរួចផុតពីបទចោទប្រកាន់ដើម្បីឱ្យពួកគាត់ទទួលបាន យុត្តិធម៌ និងសេរីភាពពេលពេញ ព្រមទាំងអាចរស់នៅប្រកបមុខរបររកស៊ីជាធម្មតាឡើងវិញ ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖**

ក្រោយពីបានពិភាក្សាដេញដោល ព្រមទាំងបានពិនិត្យទៅលើភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង រួចមក ម្យ៉ាងវិញទៀតផ្អែកតាមរយៈពេលដែលបានកំណត់នៅក្នុងសាលក្រមចាត់របៀប ដើម្បីទុកពេលវេលាឱ្យ ភាគីទាំងសងខាងដាក់ភស្តុតាងបញ្ចូលក៏ហួសពេលកំណត់ដែរ តំណាងអយ្យការយល់ឃើញថាពុំមានភស្តុតាង ណាមួយត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងឡើយ ចំណែកដើមបណ្តឹងរដ្ឋប្បវេណីគ្រាន់តែនិយាយអះអាងថាខ្លួន ជាម្ចាស់កម្មសិទ្ធិលើដីទំនាស់ ប៉ុន្តែខ្លួនមិនបានដាក់ភស្តុតាងបង្ហាញពីភាពជាម្ចាស់កម្មសិទ្ធិចូលក្នុងសំណុំរឿងដែរ ដោយឡែកពាក់ព័ន្ធការខូចខាតដោយចេតនា សូម្បីតែដើមបណ្តឹងរដ្ឋប្បវេណីក៏មិនបានឃើញសកម្មភាពដោយ ផ្ទាល់ដែរ ហើយក៏គ្មានសាក្សីណាម្នាក់ចង្អុលបង្ហាញថាជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ដែរ ហេតុដូច្នេះតំណាង អយ្យការប្តឹងសុំតុលាការឱ្យរួចផុតបទចោទទៅលើជនជាប់ចោទខាងលើ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈុនអេង និងប្រពន្ធឈ្មោះ [redacted] ដេត សុំសំណូមពរថា៖ ខ្លួនសុំ សំណូមដល់តុលាការផ្តល់យុត្តិធម៌ដល់ខ្លួន ព្រមទាំងសុំទាមទារសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗសរុបចំនួន ២០០ (ពីររយលាន) រៀល ។

-ជនជាប់ចោទឈ្មោះ [redacted] ទ្រី សំណូមពរថា៖ សំណូមពរដល់តុលាការឱ្យរួចផុតបទចោទមកលើខ្លួន ។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាន សំណូមពរថា៖ សូមមេត្តាតុលាការឱ្យខ្លួនរួចផុតបទចោទខាងលើ ។

-ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ សំណូមពរថា៖ សំណូមពរដល់តុលាការឱ្យខ្លួនបានរួចផុតបទចោទ ។

-ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា



Scanned with CamScanner

## ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់
## សាលាដំបូងខេត្តត្បូងឃ្មុំ
## យល់ឃើញថា៖

តាមដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៥១ ព្រ.១១ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ ជនជាប់ចោទឈ្មោះ [redacted] ទ្រី ,ឈ្មោះ [redacted] ស៊ីណាន ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **"រំលោភលើទំនុកចិត្ត"** ប្រព្រឹត្តនៅភូមិសំបូរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីអំឡុងឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] វិចិត្រ ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **"ធ្វើឱ្យខូចខាតដោយចេតនា"** ប្រព្រឹត្តនៅភូមិសំបូរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។ ក្រោយពីបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងអង្គសវនាការ ព្រមទាំងបានពិនិត្យនូវភស្តុតាងនានាមានក្នុងសំណុំរឿងរួចមកនាំឱ្យតុលាការបានរកឃើញថា៖

១. យោងតាមសាលក្រមព្រហ្មទណ្ឌចាត់របៀបលេខ: **២០២ "គ"** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ ដែលបានចាត់របៀបដោយបង្អង់មិនទាន់សម្រេចលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៨ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០២១ និងបានបង្គាប់ឱ្យគូភាគីរកភស្តុតាងមកដាក់ជូនតុលាការរយៈពេល ៦ ខែ គិតចាប់ពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០២១ ប៉ុន្តែរហូតមកដល់ពេលនេះពុំមានភាគីណាបានដាក់ភស្តុតាងថ្មីបញ្ចូលឡើយ ម្យ៉ាងវិញទៀតរយៈពេលចំនួន ០៦ (ប្រាំមួយ) ខែ ដែលត្រូវបានកំណត់ក្នុងសាលក្រមចាត់របៀបខាងលើក៏បានហួសពេលកំណត់ផងដែរ ដូច្នេះតុលាការនឹងមិនបន្តការបង្អង់នីតិវិធីទៀត តាមការស្នើសុំរបស់មេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីឡើយ នាំឱ្យមានការប៉ះពាល់សិទ្ធិនានាដល់ភាគីម្ខាងទៀត និងបើកសវនាការអង្គសេចក្តី ដើម្បីវិនិច្ឆ័យសម្រេចតែម្តង ។

**២.** តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទ្រី នាពេលសាវនាការបានឆ្លើយថា៖ ដីដែលខ្លួនកំពុងរស់នៅសព្វថ្ងៃមានការទិញលក់បន្ថែមជាបន្តបន្ទាប់ហើយក៏មានអាជ្ញាធរដឹងឮផងដែរ ។ ចំពោះដីនេះខ្លួនចូលមករស់តាំងពីឆ្នាំ២០០៦ មកម្លេះ ក្រោយមកនៅឆ្នាំ២០១៣ ខ្លួនបានសាងសង់ផ្ទះនៅលើដីនេះ ដោយមានការខ្វះខាតខ្លួនក៏បានខ្ចីលុយពីធនាគារក្នុងឆ្នាំ២០១៤ ចំពោះគេចោទប្រកាន់ថាខ្លួនត្រូវបានរស់នៅលើដីគេនោះវាមិនត្រឹមត្រូវទេ ។ តាមចម្លើយខាងលើផ្អែកតាមកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាក្សីឈ្មោះ [redacted] ហ៊ាង ជាមេភូមិសំបូរ បានបញ្ជាក់ថាខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ឈុនអេង នោះទេហើយឈ្មោះនេះក៏មិនមាននៅក្នុងមូលដ្ឋានភូមិសំបូររបស់ខ្លួនដែរ គ្រាន់តែដឹងថាឈ្មោះ [redacted] ឈុនអេង ត្រូវជាឪពុកមាររបស់ឈ្មោះ [redacted] ទ្រី ខ្លួនមិនដឹងថាឈ្មោះ [redacted] ឈុនអេង មានដីឬអត់នៅក្នុងភូមិនោះទេ ប៉ុន្តែចាប់តាំងពីខ្លួនក្លាយជាមេភូមិមក ខ្លួនឃើញតែឈ្មោះ [redacted] ទ្រី ជាអ្នករស់នៅលើដីទំនាស់នេះ ដោយមិនដែលឃើញឈ្មោះ [redacted] ឈុនអេង មកកាន់កាប់លើដីនោះ ឬតវ៉ាអ្វីឡើយ ។ ហេតុដូច្នេះគប្បីតុលាការពិចារណាសម្រេចឱ្យរួចផុតបទចោទលើជនជាប់ចោទរូបនេះ ។



Scanned with CamScanner

៣. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាន នាពេលសាវនាការបានឆ្លើយថា៖ ខ្លួនបានរស់នៅលើសព្វថ្ងៃនេះតាំងពីឆ្នាំ២០០៦ មកម្ល៉េះហើយនៅឆ្នាំ២០១៣ ខ្លួន និងប្តីបានធ្វើផ្ទះរស់នៅអស់ប្រហែល ២ ម៉ឺនដុល្លារអាមេរិក ចំពោះការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកថាខ្លួនជាអ្នកចេញថ្លៃសាងសង់នោះមិនពិតឡើយ ។ តុលាការយល់ឃើញថាការលើកឡើងរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាន គឺពិតជាត្រឹមត្រូវដោយហេតុថាតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ដែន ដែលជាជាងសាងសង់ផ្ទះឱ្យឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ស៊ីណាន បានបញ្ជាក់ថាខ្លួនយកថ្លៃឈ្នួលសរុប ២,៥០០ (ពីរពាន់ប្រាំរយដុល្លារ) អាមេរិក ដោយឈ្មោះ [redacted] ទ្រី ជាអ្នកឱ្យខ្លួននិងឪពុករបស់ខ្ញុំផ្ទាល់ដៃ ម្យ៉ាងវិញទៀតសម្ភារៈសម្រាប់សាងសង់ ខ្សាច់ ,ថ្ម ,គ្រឿង និងសម្ភារៈផ្សេងៗទៀតគឺម្ចាស់ផ្ទះ និងឪពុករបស់ខ្លួនជាអ្នកទៅទិញនៅផ្សារមេមត់ ។ តុលាការយល់ឃើញថាគ្មានភស្តុតាងដាក់បន្ទុកអំពីពិរុទ្ធភាពណាមួយត្រូវបានជាប់ពាក់ព័ន្ធជនជាប់ចោទរូបនេះទេ គប្បីតុលាការពិចារណាឱ្យរួចផុតពីបទចោទខាងលើ ។

៤. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ បានឆ្លើយថា៖ ចំពោះដើមបណ្តឹងថាគាត់ជាអ្នកចំណាយលើរៀបការរបស់ខ្លួនគឺមិនពិតនោះទេគាត់មិនបានរៀបចំការឱ្យខ្លួនទេ គឺខ្លួនគ្រាន់តែសុំផ្ទះរបស់គាត់ថតរូបតែប៉ុណ្ណោះព្រោះផ្ទះគាត់ធំហើយស្អាត តុលាការយល់ឃើញថាការឆ្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ វាជារឿងសមហេតុផលពីព្រោះការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណី វាគ្រាន់តែបានអះអាងថាខ្លួនជាអ្នកចំណាយលើការរៀបអាពាហ៍ពិពាហ៍របស់ឈ្មោះ [redacted] វិចិត្រ (ចៅ) ប៉ុន្តែរហូតមកដល់ពេលនេះមិនមានភស្តុតាងអ្វីមកបញ្ជាក់ឡើយ ហើយក៏មិនមានសាក្សីណាម្នាក់ផ្តល់សក្ខីភាពគាំទ្រការអះអាងរបស់ដើមបណ្តឹងដែរ ។

៥. តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈុនអេង បានឆ្លើយថា៖ នៅក្នុងឆ្នាំ២០០៦ ខ្លួនបានទិញដីពីឈ្មោះ [redacted] វណ្ណា ចំនួន ០១ (មួយ) ហិចតា ក្នុងតម្លៃ ៤,០០០ (បួនពាន់ដុល្លារ) អាមេរិក ហើយដាំដើមទុរេនបានស្រាប់ហើយ ហើយមានស្រះស្រីស្រាប់ទៀតផង ចំពោះដីនោះខ្លួនរវល់ក៏បានឱ្យជនជាប់ចោទជាក្មួយមករស់នៅមើលថែព្រមទាំងមានក្មួយៗផ្សេងទៀត ត្រង់ចំណុចនេះតុលាការយល់ឃើញថាគ្មានលិខិតជាឯកសារណាបញ្ជាក់អំពីការទិញ-លក់នោះទេ ម្យ៉ាងវិញទៀតដើមបណ្តឹងរដ្ឋប្បវេណីក៏មិនបានដាក់ឈ្មោះ [redacted] វណ្ណា ធ្វើជាសាក្សីដើម្បីការពារអំណះអំណាងរបស់ខ្លួនដែរ គប្បីតុលាការមិនយកមកពិចារណាសម្រេចតាមការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ចំណែកការលើកឡើងថាឆ្នាំជិតការកូនវា (ចៅ) ទើបប្រពន្ធរបស់ខ្ញុំប្រាប់ឱ្យវាធ្វើផ្ទះឱ្យមានមុខមានមាត់ ចំពោះជាងកូនក្មួយជាអ្នករកខ្លួនឯង ចំពោះសម្ភារៈដូចជាស៊ីម៉ង់ ដែក ឥដ្ឋ ខ្លួនជាអ្នកចេញលុយទាំងអស់ តុលាការមិនអាចជឿបានទេ ព្រោះជនជាប់ចោទមានសាក្សីជាជាងផ្ទះបានអះអាងត្រឹមត្រូវអំពីការសាងសង់ ថ្លៃឈ្នួល ការទិញសម្ភារៈសំណង់ផ្សេងៗ ។ រីឯការដែលលើកឡើងថាយ៉ាងហោចណាស់ក្នុង ០១ (មួយ) ខែ ខ្លួនទៅមើល ៣ (ដង) ដែរ ហើយមានអ្នកដឹងឮតែខ្ញុំមិនបានហៅគេចូលរួមធ្វើជាសាក្សី តុលាការកាន់តែមិនអាចជឿបានឡើយ ដោយហេតុថាសាក្សីជាមេភូមិ និងមេឃុំមិនដែលដឹងអំពីវត្តមានរបស់ដើមបណ្តឹងឈ្មោះ នាង ឈុនអេង នេះរស់នៅចេញចូលក្នុងភូមិរបស់ខ្លួនដែរ ។ ជាសរុបមកតុលាការយល់ឃើញថាការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនមានបន្ទុកគ្រប់គ្រាន់ក្នុងចោទប្រកាន់ទៅលើជនជាប់ចោទនោះទេ ។



Scanned with CamScanner

៦. សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការរួចមក ដោយសារកន្លងមកខ្លួនបានដាក់ពាក្យបង្អង់នីតិវិធីរួចចូលមកម្ដងរួចហើយ ដើម្បីរងចាំដាក់ភស្ដុតាងបញ្ចូល ប៉ុន្ដែរហូតមកដល់ពេលនេះក្នុងនាមជាមេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនស្នើសុំតុលាការមេត្ដាផ្ដល់យុត្តិធម៌ដល់កូនក្ដី និងធ្វើការផ្ដន្ទាទោសតាមច្បាប់លើជនជាប់ចោទខាងលើ ។ តុលាការនឹងមិនលើកយកមកពិចារណាតាមការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ។

៧. សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ យោងតាមសេចក្ដីសន្និដ្ឋានការពារចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ តុលាការយល់ឃើញថាសមហេតុផល និងត្រឹមត្រូវតាមគតិច្បាប់ គប្បីតុលាការពិចារណាសម្រេចតាមការប្ដឹងសុំរបស់មេធាវីការពារជនជាប់ចោទ ។

៨. កន្លងមកជនជាប់ចោទបានដាក់ប្រាក់តម្កល់ចំនួន ២ (ពីរលាន) រៀល នៅដំណាក់កាលស៊ើបសួរដើម្បីធានាដល់ការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់មកពេលនេះការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបានបញ្ចប់ យោងតាមមាត្រា ៣៥២ នៃក្រមព្រហ្មទណ្ឌ ដូច្នេះគប្បីតុលាការបង្គាប់ឲ្យប្រគល់ប្រាក់តម្កល់នោះត្រឡប់ទៅឲ្យជនជាប់ចោទវិញ ។

៩. ក្រោយពីបានពិភាក្សាដេញដោល ព្រមទាំងបានពិនិត្យទៅលើភស្ដុតាងនានាដែលមាននៅក្នុងសំណុំរឿងរួចមក ម្យ៉ាងវិញទៀតផ្អែកតាមរយៈពេលដែលបានកំណត់នៅក្នុងសាលក្រមចាត់របៀប ដើម្បីទុកពេលវេលាឲ្យភាគីទាំងសងខាងដាក់ភស្ដុតាងបញ្ចូលក៏ហួសពេលកំណត់ដែរ រហូតតំណាងអយ្យការយល់ឃើញថាពុំមានភស្ដុតាងណាមួយត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងឡើយ ចំណែកដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែនិយាយអះអាងថាខ្លួនជាម្ចាស់កម្មសិទ្ធិលើដីទំនាស់ ប៉ុន្ដែខ្លួនមិនបានដាក់ភស្ដុតាងបង្ហាញពីភាពជាម្ចាស់កម្មសិទ្ធិចូលក្នុងសំណុំរឿងទេ ដោយឡែកពាក់ព័ន្ធការខូចខាតដោយចេតនា សូម្បីតែដើមបណ្ដឹងរដ្ឋប្បវេណីក៏មិនបានឃើញសកម្មភាពដោយផ្ទាល់ដែរ ហើយក៏គ្មានសាក្សីណាម្នាក់ចង្អុលបង្ហាញថាជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ជាអ្នកអ្នកប្រព្រឹត្តដែរ ហេតុដូច្នេះតំណាងអយ្យការប្ដឹងសុំតុលាការឲ្យរួចផុតបទចោទទៅលើជនជាប់ចោទខាងលើ ។ ចំពោះការប្ដឹងសុំរបស់តំណាងអយ្យការ តុលាការយល់ឃើញថាមានភាពត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ គប្បីតុលាការសម្រេចតាមការប្ដឹងសុំរបស់តំណាងអយ្យការ ។

១០. ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឈុនអេង** និងប្រពន្ធឈ្មោះ [redacted] **ឈេត** សុំសំណូមពរថា៖ ខ្លួនសុំសំណូមដល់តុលាការផ្ដល់យុត្តិធម៌ដល់ខ្លួន ព្រមទាំងសុំទាមទារសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗសរុបចំនួន ២០០ (ពីររយលាន) រៀល ។ តុលាការនឹងមិនពិចារណាតាមការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ។

១១. ជនជាប់ចោទឈ្មោះ [redacted] ទ្រី សំណូមពរថា៖ សំណូមពរដល់តុលាការឲ្យខ្លួនរួចផុតពីបទចោទមកលើខ្លួន តុលាការនឹងពិចារណាសម្រេចតាមការសំណូមពរ ។

១២. ជនជាប់ចោទឈ្មោះ [redacted] **ស៊ីណាន** សំណូមពរថា៖ សំណូមពរដល់តុលាការឲ្យខ្លួនរួចផុតពីបទចោទមកលើខ្លួន តុលាការនឹងពិចារណាសម្រេចតាមការសំណូមពរ ។

១៣. ជនជាប់ចោទឈ្មោះ [redacted] **វិចិត្រ** សំណូមពរថា៖ សំណូមពរដល់តុលាការឲ្យខ្លួនរួចផុតពីបទចោទមកលើខ្លួន តុលាការនឹងពិចារណាសម្រេចតាមការសំណូមពរ

**១៤. សរុបជារួមមក៖** យោងតាមទឡ្ហីករណ៍ដែលបានលើកឡើងខាងលើ តុលាការជឿជាក់បានថាគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ទ្រី ,ឈ្មោះ [redacted] ស៊ីណាន (សវតារជាតិដូចខាងលើ) ពីបទ **"រំលោភលើទំនុកចិត្ត"** ប្រព្រឹត្តនៅចំណុចភូមិសំបួរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីឆ្នាំ ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] វិចិត្រ (សវតារជាតិដូចខាងលើ) ពីបទ **"ធ្វើឱ្យខូចខាតដោយចេតនា"** ប្រព្រឹត្តនៅចំណុចភូមិសំបួរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌនោះឡើយ គប្បីតុលាការឱ្យរួចផុតបទចោទ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្ដី

**១. ឱ្យរួចផុតបទចោទលើ៖**

- ឈ្មោះ [redacted] ទ្រី ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ)
- ឈ្មោះ [redacted] ស៊ីណាន ភេទស្រី អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ)

ពីបទ **"រំលោភលើទំនុកចិត្ត"** ប្រព្រឹត្តនៅចំណុចភូមិសំបួរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីឆ្នាំ ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ ៣០ឆ្នាំ ជាទីតិជន ជនជាតិខ្មែរ (មានសាវតារជាតិខាងលើ)

ពីបទ **"ធ្វើឱ្យខូចខាតដោយចេតនា"** ប្រព្រឹត្តនៅចំណុចភូមិសំបួរ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

**២.** សាលក្រមព្រហ្មទណ្ឌនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី**២១** ខែ**មករា** ឆ្នាំ**២០២៣** និងប្រកាសជាសាធារណៈនៅថ្ងៃទី**២៨** ខែ**កុម្ភៈ** ឆ្នាំ**២០២៣** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទ្រី ,ឈ្មោះ [redacted] ស៊ីណាន និងឈ្មោះ [redacted] វិចិត្រ និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដេត និងចាត់ទុកចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈុនអេង ។

ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និងត្រាក្រឡាបញ្ជី៖** [redacted]

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រាចៅក្រម៖** [redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**បានឃើញ**

ខេត្តត្បូងឃ្មុំ, ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

[redacted]

ថ្ងៃអង្គារ ៩ កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តត្បូងឃ្មុំ, ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner